**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**

# កំណត់ហេតុ

ស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន **ភី ភី អេស អ៊ី ស៊ី ឯ.ក** ឆ្នាំពីរពាន់ម្ភៃប្រាំ ខែមេសា ថ្ងៃទីម្ភៃមួយ វេលាម៉ោងដប់ និងម្ភៃនាទី នៅការិយាល័យនៃក្រុមហ៊ុនមានបើកប្រជុំសាកសួរព័ត៌មាន ស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន **ភី ភី អេស អ៊ី ស៊ី ឯ.ក** ដោយគិតចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ រហូតដល់ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ១២៧នាក់ (ស្រី៥៥នាក់) ក្នុងកម្មករនិយោជិតសរុបចំនួន ៥៨៨នាក់ (ស្រី ២១១នាក់) ដែលស្ថិតក្នុងកិច្ចសន្យាការងារមានថិរវេលាកំណត់ចំនួន ០០នាក់ (ស្រី ០០នាក់) និងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ចំនួន ៥៨៨នាក់ (ស្រី ២១១នាក់) ។

ក្រោមអធិបតីភាពរបស់**លោក សុះ សោភ័ណ** ជាអនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ នៃនាយកដ្ឋានអធិការកិច្ចការងារ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**<u>អញ្ជើញចូលរួមក្នុងឱកាសនោះរួមមាន</u>**

១- **<u>ខាងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>**

| | | |
|---|---|---|
| លោក | សុះ សោភ័ណ | អនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ |
| លោក | ជៀង សុជាត | អនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ |

២- **<u>ខាងតំណាងនិយោជកមាន</u>**

| | | |
|---|---|---|
| លោកស្រី | ហ៊ើល សែន | ប្រធានរដ្ឋបាល |

**<u>យោបល់របស់តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>**

ជាកិច្ចចាប់ផ្តើមលោក **សុះ សោភ័ណ** ប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់តំណាងនិយោជកទាំងអស់ដែលបានអញ្ជើញចូលរួមផ្តល់ព័ត៌មានបំភ្លឺ ស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនមួយរយៈនាពេលខាងមុខ។ បន្ទាប់មក **លោក សុះ សោភ័ណ** ជាប្រធានអង្គប្រជុំបានសាកសួរព័ត៌មានផ្សេងៗ បន្ថែមទៀតស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនចំពោះកម្មករនិយោជិតនិងអត្ថប្រយោជន៍ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។ **<u>យោបល់របស់តំណាងនិយោជក</u>** ឆ្លើយតបនឹងប្រសាសន៍របស់ **លោក សុះ សោភ័ណ** ជាប្រធានអង្គប្រជុំ តំណាងនិយោជកនៃក្រុមហ៊ុនបានផ្តល់ព័ត៌មានយ៉ាងល្អិតល្អន់ដូចតទៅ៖

តំណាងនិយោជកនៃក្រុមហ៊ុនបានឱ្យដឹងថា មួយរយៈនេះក្រុមហ៊ុនខ្វះវត្ថុធាតុដើម ទើបក្រុមហ៊ុនបានប្រជុំជាមួយនឹងតំណាងបងប្អូនកម្មករនិយោជិត ដោយឯកភាពគ្នាក្នុងការព្យួរកិច្ចសន្យាការងារ រយៈពេល១៧ថ្ងៃ ដោយគិតចាប់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ១២៧នាក់ (ស្រី ៥៥នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥៨៨នាក់ (ស្រី ២១១នាក់)។

នាយកក្រុមហ៊ុនបានព្រមព្រៀងដោយផ្តល់ប្រាក់ឧបត្ថម្ភ ៥០ភាគរយ នៃប្រាក់ឈ្នួលអប្បរមា ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។ ចំពោះប្រាក់ឧបត្ថម្ភក្រុមហ៊ុននឹងផ្តល់ជូនទៅបងប្អូនកម្មករនិយោជិតម្នាក់ៗនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ ដោយបើកតាមធនាគារអេស៊ីលីដា។ ករណីម្ចាស់ នាយក ឬតំណាងរោងចក្រ សហគ្រាសមិនបានផ្ញើឯកសារព្យួរកិច្ចសន្យាការងារបានត្រឹមត្រូវ ទៅកាន់ប្រព័ន្ធព្យួរកិច្ចសន្យាការងារទាន់ពេលវេលាទេ ម្ចាស់ នាយក ឬតំណាងរោងចក្រសហគ្រាសនឹងទទួលខុសត្រូវចំពោះច្បាប់ស្តីពីការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត បន្ទាប់ពីបញ្ចប់ចិរវេលានៃការព្យួរកិច្ចសន្យាការងារបងប្អូនកម្មករនិយោជិត នឹងចូលបម្រើការងារជាធម្មតាវិញនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥ ហើយរក្សាតួនាទីភារកិច្ច និងអត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិតនៅដដែល។ មួយវិញទៀតចំពោះប្រាក់បំណាច់អតីតភាពការងារ និងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ក្រុមហ៊ុនបានផ្តល់ជូនបងប្អូនកម្មករនិយោជិតបានត្រឹមត្រូវរួចរាល់ស្របតាមច្បាប់កំណត់ហើយ ឆមាសទី១ និងឆមាសទី២ ក្នុងឆ្នាំ២០២៤ នេះក៏ក្រុមហ៊ុនបានទូទាត់ជូនបងប្អូនកម្មករនិយោជិតរួចរាល់អស់ហើយដែរ។

ក្នុងករណីនាយកក្រុមហ៊ុនមានការងារជូនបងប្អូនកម្មករនិយោជិតធ្វើមុនថ្ងៃកំណត់ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងជូនដំណឹងទៅក្រសួងតាមប្រព័ន្ធអនឡាញ បន្ទាប់មកក្រុមហ៊ុននឹងជូនដំណឹងតាមរយៈលេខទូរស័ព្ទរដ្ឋបាល ប្រធានផ្នែក ឬប្រធានក្រុមឱ្យបងប្អូនកម្មករនិយោជិតចូលធ្វើការងារវិញ មុនថ្ងៃបញ្ចប់ព្យួរកិច្ចសន្យាការងារ ប្រសិនបើក្រុមហ៊ុននៅតែគ្មានការងារជូនបងប្អូនកម្មករនិយោជិតបានធ្វើក្រុមហ៊ុននឹងបន្តការព្យួរតាមការកំណត់។ ចំពោះបងប្អូនកម្មករនិយោជិតណាដែលមិនបានត្រឡប់មកបម្រើការងារទាន់ពេលវេលាតាមកាលកំណត់ នៃការព្យួរកិច្ចសន្យាការងារ នឹងត្រូវអនុវត្តទៅតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥

| | | |
|---|---|---|
| បានឃើញ និងឯកភាព<br>ប្រធានអង្គប្រជុំ | បានឃើញ និងឯកភាព<br>អ្នកផ្តល់ព័ត៌មាន | អ្នកកត់ត្រា |
| **សុះ សោភ័ណ** | ព្រះរាជាណាចក្រកម្ពុជា<br>ក្រុមហ៊ុន<br>ភី ភី អេស អ៊ី ស៊ី ឯ.ក<br>P P S E C COMPANY<br>LIMITED<br>KINGDOM OF CAMBODIA<br>**ហ៊ើល សែន** | **ជៀង សុផាត** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**

# កំ ណ ត់ ហេ តុ

ស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន**ភី ភី អេស អ៊ី ស៊ី ឯ.ក** ឆ្នាំពីរពាន់ម្ភៃប្រាំ ខែមេសា ថ្ងៃទីម្ភៃមួយ វេលាម៉ោងដប់ និងម្ភៃនាទី នៅការិយាល័យនៃក្រុមហ៊ុនមានបើកប្រជុំសាកសួរព័ត៌មាន ស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន **ភី ភី អេស អ៊ី ស៊ី ឯ.ក** ដោយគិតចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ រហូតដល់ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ១២៧នាក់ (ស្រី៥៥នាក់) ក្នុងកម្មករនិយោជិតសរុបចំនួន ៥៨៨នាក់ (ស្រី ២១១នាក់) ដែលស្ថិតក្នុងកិច្ចសន្យាការងារមានថិរវេលាកំណត់ចំនួន ០០នាក់ (ស្រី ០០នាក់) និងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ចំនួន ៥៨៨នាក់ (ស្រី ២១១នាក់) ។

ក្រោមអធិបតីភាពរបស់**លោក សុះ សោភ័ណ** ជាអនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ នៃនាយកដ្ឋានអធិការកិច្ចការងារ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**<u>អញ្ជើញចូលរួមក្នុងឱកាសនោះ រួមមាន</u>**

១- **<u>ខាងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>**

| | | |
|---|---|---|
| **លោក** | **សុះ សោភ័ណ** | អនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ |
| **លោក** | **ជៀង សូជាត** | អនុប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៤ |

២- **ខាងតំណាងកម្មករនិយោជិតមាន**

| | | |
|---|---|---|
| **លោកស្រី** | **នេត ស្រីពៅ** | ប្រតិភូបុគ្គលិក |
| **លោកស្រី** | **ពេញ ស្រីណែត** | ប្រតិភូបុគ្គលិក |
| **លោក** | **ម៉ម សីមុន្នី** | ប្រតិភូបុគ្គលិក |
| **លោក** | **ឃីម សុគន្ធ** | ប្រតិភូបុគ្គលិក |
| **លោក** | **ថន គីមមួយ** | ប្រតិភូបុគ្គលិក |

**យោបល់របស់តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ជាកិច្ចចាប់ផ្តើម**លោក សុះ សោភ័ណ** ប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់តំណាងកម្មករនិយោជិតទាំងអស់ដែលបានអញ្ជើញចូលរួមផ្តល់ព័ត៌មានបំភ្លឺ ស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនមួយរយៈនាពេលខាងមុខ។ បន្ទាប់មក **លោក សុះ សោភ័ណ** ជាប្រធានអង្គប្រជុំក៏បានសាកសួរព័ត៌មានផ្សេងៗ បន្ថែមទៀតស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន ចំពោះតំណាងបងប្អូនកម្មករនិយោជិតនិងអត្ថប្រយោជន៍ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។

**<u>យោបល់របស់តំណាងកម្មករនិយោជិត</u>**

ឆ្លើយតបនឹងប្រសាសន៍របស់**លោក សុះ សោភ័ណ** ជាប្រធានអង្គប្រជុំ តំណាងបងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនបានផ្តល់ព័ត៌មានយ៉ាងល្អិតល្អន់ដូចតទៅ៖ តំណាងបងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនបានឱ្យដឹងថា មួយរយៈនេះក្រុមហ៊ុនខ្វះវត្ថុធាតុដើម ទើបក្រុមហ៊ុនបានប្រជុំជាមួយនឹងតំណាងបងប្អូនកម្មករនិយោជិត ដោយឯកភាពគ្នាក្នុងការព្យួរកិច្ចសន្យាការងារ រយៈពេល១៧ថ្ងៃ ដោយគិតចាប់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ១២៧នាក់ (ស្រី ៥៥នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥៨៨នាក់ (ស្រី ២១១នាក់)។

នាយកក្រុមហ៊ុនបានព្រមព្រៀងដោយផ្តល់ប្រាក់ឧបត្ថម្ភ ៥០ភាគរយ នៃប្រាក់ឈ្នួលអប្បរមា ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។ ចំពោះប្រាក់ឧបត្ថម្ភក្រុមហ៊ុននឹងផ្តល់ជូនទៅបងប្អូនកម្មករនិយោជិតម្នាក់ៗនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ ដោយបើកតាមធនាគារអេស៊ីលីដា។ ករណីម្ចាស់ នាយក ឬតំណាងរោងចក្រ សហគ្រាសមិនបានផ្ញើឯកសារព្យួរកិច្ចសន្យាការងារបានត្រឹមត្រូវ ទៅកាន់ប្រព័ន្ធព្យួរកិច្ចសន្យាការងារទាន់ពេលវេលាទេ ម្ចាស់ នាយក ឬតំណាងរោងចក្រសហគ្រាសនឹងទទួលខុសត្រូវចំពោះច្បាប់ស្តីពីការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត បន្ទាប់ពីបញ្ចប់ចិរវេលានៃការព្យួរកិច្ចសន្យាការងារ បងប្អូនកម្មករនិយោជិត នឹងចូលបម្រើការងារជាធម្មតាវិញនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥ ហើយរក្សាតួនាទីភារកិច្ច និងអត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិតនៅដដែល។ មួយវិញទៀតចំពោះប្រាក់បំណាច់អតីតភាពការងារ និងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ក្រុមហ៊ុនបានផ្តល់ជូនបងប្អូនកម្មករនិយោជិតបានត្រឹមត្រូវរួចរាល់ស្របតាមច្បាប់កំណត់ហើយ ឆមាសទី១ និងឆមាសទី២ ក្នុងឆ្នាំ២០២៤ នេះក៏ក្រុមហ៊ុនបានទូទាត់ជូនបងប្អូនកម្មករនិយោជិតរួចរាល់អស់ហើយដែរ។

ក្នុងករណីនាយកក្រុមហ៊ុនមានការងារជូនបងប្អូនកម្មករនិយោជិតធ្វើមុនថ្ងៃកំណត់ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងជូនដំណឹងទៅក្រសួងតាមប្រព័ន្ធអនឡាញ បន្ទាប់មកក្រុមហ៊ុននឹងជូនដំណឹងតាមរយៈលេខទូរស័ព្ទរដ្ឋបាល ប្រធានផ្នែក ឬប្រធានក្រុម ឱ្យបងប្អូនកម្មករនិយោជិតចូលធ្វើការងារវិញ មុនថ្ងៃបញ្ចប់ព្យួរកិច្ចសន្យាការងារ ប្រសិនបើក្រុមហ៊ុននៅតែគ្មានការងារជូនបងប្អូនកម្មករនិយោជិតបានធ្វើក្រុមហ៊ុននឹងបន្តការព្យួរតាមការកំណត់។ ចំពោះបងប្អូនកម្មករនិយោជិតណាដែលមិនបានត្រឡប់មកបម្រើការងារទាន់ពេលវេលាតាមកាលកំណត់ នៃការព្យួរកិច្ចសន្យាការងារ នឹងត្រូវអនុវត្តទៅតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំពីរ និងដប់ប្រាំនាទី នាថ្ងៃ ខែ ឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥

| | | |
|---|---|---|
| បានឃើញ និងឯកភាព<br>ប្រធានអង្គប្រជុំ | បានឃើញ និងឯកភាព<br>អ្នកផ្តល់ព័ត៌មាន | អ្នកកត់ត្រា |
| **សុះ សោភ័ណ** | **នេត ស្រីពៅ** | **ជៀង សុផាត** |

**ពេញ ស្រីណែត** **ម៉ម សីមុន្នី** **ឃីម សុគន្ធ** **ថន គីមមួយ**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានវិវាទការងារ**
លេខ: E1SS202401956 វក

**ជម្រាបមក**
**លោក នាយករោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក**

**កម្មវត្ថុ ៖** ការទទួលស្គាល់ប្រតិភូបុគ្គលិកដែលបានជាប់ឆ្នោតប្រចាំរោងចក្រអាណត្តិទី៤
**យោង ៖** កំណត់ហេតុស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងសូមជម្រាប **លោក** ជ្រាបថា ក្រសួងសម្រេចទទួលស្គាល់ប្រតិភូបុគ្គលិកដែលបានជាប់ឆ្នោតប្រចាំរោងចក្រអាណត្តិទី៤។

ដើម្បីឱ្យកម្មករនិយោជិតទាំងអស់ក្នុងរោងចក្ររបស់ **លោក** បានជ្រាបអំពីលទ្ធផលនៃការបោះឆ្នោតនេះ និងដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រតិភូបុគ្គលិកជំនួយដែលទើបជាប់ឆ្នោតបំពេញភារកិច្ចរបស់ខ្លួនបានល្អ សូម **លោក** អនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសលេខ៣០២ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨។ ចំពោះមុខ **លោក** ត្រូវ៖

- យកកំណត់ហេតុស្តីពីការបោះឆ្នោតនេះទៅបិទផ្សព្វផ្សាយក្នុងរោងចក្រ
- ផ្ដល់ទីកន្លែងធ្វើការសមស្រប និងពេលវេលាយ៉ាងតិចពីរម៉ោងក្នុងមួយសប្ដាហ៍ ដល់ប្រតិភូបុគ្គលិកពេញសិទ្ធិម្នាក់ៗ សម្រាប់បំពេញការងាររបស់ខ្លួន ដោយរក្សាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំផ្សេងៗ ដែលធ្លាប់ទទួលបាននៅដដែល។

អាណត្តិរបស់ប្រតិភូបុគ្គលិកមានរយៈពេល ២(ពីរ)ឆ្នាំ ផុតកំណត់ត្រឹមថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក** អនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់នេះ។

ថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤
**ចេញដោយ នាយកដ្ឋានវិវាទការងារ**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភី ភី អេស អ៊ី ស៊ី ឯ.ក
P P S E C COMPANY
LIMITED

ទិន្នន័យដែលត្រឹមត្រូវ គឺមាននៅលើគេហទំព័រ
https://www.lacms.mlvt.gov.kh

**ចម្លងជូន**:
-លោកស្រី រ៉េត ស្រីម៉ី
-លេខទូរស័ព្ទ៖ 096 917 8007

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**:
-លេខទូរស័ព្ទ៖ 1297

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុស្តីពី**
**ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិទី៤**
**ប្រចាំសហគ្រាស ភី ភី អេស អ៊ី ស៊ី ៦.ក**

ឆ្នាំពីរពាន់ម្ភៃបួន ខែកញ្ញា ថ្ងៃទីម្ភៃប្រាំមួយ វេលាម៉ោងដប់បួនរសៀល នៅទីស្នាក់ការសហគ្រាស **ភី ភី អេស អ៊ី ស៊ី ៦.ក** ដែលមានអាសយដ្ឋាននៅផ្លូវជាតិលេខ៤ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិបឹងធំទី៣ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ មានរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិទី៤ ប្រចាំសហគ្រាស ក្រោមអធិបតីភាពលោក **HWANG SOON JUNG** ម្ចាស់ឬនាយកសហគ្រាស ដែលក្នុងនោះមានកម្មករនិយោជិត ចូលរួមសរុបចំនួន**៦៤៥**នាក់ (ស្រី**២៩៩**នាក់) លើកម្មករនិយោជិតសរុប**៦៤៥**នាក់ (ស្រី**២៩៩**នាក់)។

**គណៈកម្មការរៀបចំការបោះឆ្នោតរួមមាន៖**

| | |
|---|---|
| ១-ឈ្មោះ **Hwang Soon Jung** | ម្ចាស់ ឬនាយក និងជាប្រធានអង្គប្រជុំ |
| ២-ឈ្មោះ *ហៃាល សៃន* | ជាលេខាកត់ត្រា |
| ៣-ឈ្មោះ.................................... | .................................... |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ៦.ក P P S E C COMPANY LIMITED KINGDOM OF CAMBODIA

**គណៈទី១៖**

**បេក្ខជនឈរឈ្មោះជាប្រតិភូបុគ្គលិកពេញសិទ្ធិ និងសំឡេងឆ្នោតទទួលបាន៖**

| | | | |
|---|---|---|---|
| ១-ឈ្មោះ គីម សុគន្ធ | អាយុ២៧ឆ្នាំ | អតីតភាពការងារ២៥ខែ/ឆ្នាំ | ទទួលបាន១៤២សំឡេង |
| ២-ឈ្មោះ នេត ស្រីពៅ | អាយុ២៩ឆ្នាំ | អតីតភាពការងារ៦៥ខែ/ឆ្នាំ | ទទួលបាន៩២សំឡេង |
| ៣-ឈ្មោះ មាស ណាហ្គា | អាយុ២៣ឆ្នាំ | អតីតភាពការងារ៤៦ខែ/ឆ្នាំ | ទទួលបាន៦៧សំឡេង |
| ៤-ឈ្មោះ គុណ គីមយុន | អាយុ៣៣ឆ្នាំ | អតីតភាពការងារ៤៦ខែ/ឆ្នាំ | ទទួលបាន៥០សំឡេង |

**បេក្ខជនឈរឈ្មោះជាប្រតិភូបុគ្គលិកជំនួយ និងសំឡេងឆ្នោតទទួលបាន៖**

| | | | |
|---|---|---|---|
| ១-ឈ្មោះ កែត កែវ | អាយុ២៣ឆ្នាំ | អតីតភាពការងារ៣៤ខែ/ឆ្នាំ | ទទួលបាន៣៤សំឡេង |
| ២-ឈ្មោះ រ៉េត ស្រីមី | អាយុ២១ឆ្នាំ | អតីតភាពការងារ២៥ខែ/ឆ្នាំ | ទទួលបាន៣១សំឡេង |
| ៣-ឈ្មោះ វ៉ា សុវណ្ណឌី | អាយុ២៩ឆ្នាំ | អតីតភាពការងារ៥៨ខែ/ឆ្នាំ | ទទួលបាន២៦សំឡេង |
| ៤-ឈ្មោះ តេង ហៀង | អាយុ៣០ឆ្នាំ | អតីតភាពការងារ១២ខែ/ឆ្នាំ | ទទួលបាន២៥សំឡេង |

**គណៈទី២៖**

**បេក្ខជនឈរឈ្មោះជាប្រតិភូបុគ្គលិកពេញសិទ្ធិ និងសំឡេងឆ្នោតទទួលបាន៖**

| | | | |
|---|---|---|---|
| ១-ឈ្មោះ ឆុំ សុភា | អាយុ២០ឆ្នាំ | អតីតភាពការងារ១៩ខែ/ឆ្នាំ | ទទួលបាន២៥សំឡេង |
| ២-ឈ្មោះ សំ សុអ៊ីម | អាយុ២៧ឆ្នាំ | អតីតភាពការងារ៦៣ខែ/ឆ្នាំ | ទទួលបាន១៥សំឡេង |
| ៣-ឈ្មោះ បូ មករា | អាយុ៣២ឆ្នាំ | អតីតភាពការងារ៤៨ខែ/ឆ្នាំ | ទទួលបាន១៤សំឡេង |
| ៤-ឈ្មោះ ចែម គីមលុច | អាយុ៣២ឆ្នាំ | អតីតភាពការងារ៥៧ខែ/ឆ្នាំ | ទទួលបាន១៤សំឡេង |

**បេក្ខជនឈរឈ្មោះជាប្រតិភូបុគ្គលិកជំនួយ និងសំឡេងឆ្នោតទទួលបាន៖**

| | | | |
|---|---|---|---|
| ១-ឈ្មោះ ថន គីមមួយ | អាយុ២០ឆ្នាំ | អតីតភាពការងារ១២ខែ/ឆ្នាំ | ទទួលបាន១៣សំឡេង |
| ២-ឈ្មោះ ពេញ ស្រីណែត | អាយុ៣៥ឆ្នាំ | អតីតភាពការងារ៦៥ខែ/ឆ្នាំ | ទទួលបាន១២សំឡេង |
| ៣-ឈ្មោះ ពេញ បូរិន | អាយុ៣០ឆ្នាំ | អតីតភាពការងារ២៩ខែ/ឆ្នាំ | ទទួលបាន០៩សំឡេង |
| ៤-ឈ្មោះ ម៉ម សីមុន្នី | អាយុ៣៣ឆ្នាំ | អតីតភាពការងារ៥៩ខែ/ឆ្នាំ | ទទួលបាន០៧សំឡេង |

**លទ្ធផលនៃការបោះឆ្នោត គណៈទី១៖**

| | |
|---|---|
| បេក្ខជនជាប់ជាប្រតិភូបុគ្គលិកពេញសិទ្ធិ | បេក្ខជនជាប់ជាប្រតិភូបុគ្គលិកជំនួយ |
| ១-ឈ្មោះ គីម សុគន្ធ | ១-ឈ្មោះ កែត កែវ |
| ២-ឈ្មោះ នេត ស្រីពៅ | ២-ឈ្មោះ រ៉េត ស្រីមី |
| ៣-ឈ្មោះ មាស ណាហ្គា | ៣-ឈ្មោះ វ៉ា សុវណ្ណឌី |
| ៤-ឈ្មោះ គុណ គីមឃុន | ៤-ឈ្មោះ តេង ហៀង |

**លទ្ធផលនៃការបោះឆ្នោត គណៈទី២៖**

| | |
|---|---|
| បេក្ខជនជាប់ជាប្រតិភូបុគ្គលិកពេញសិទ្ធិ | បេក្ខជនជាប់ជាប្រតិភូបុគ្គលិកជំនួយ |
| ១-ឈ្មោះ ធុំ សុភា | ១-ឈ្មោះ ថន គីមមួយ |
| ២-ឈ្មោះ សំ សុអ៊ីម | ២-ឈ្មោះ ពេញ ស្រីណែត |
| ៣-ឈ្មោះ បូ មករា | ៣-ឈ្មោះ ពេញ បូរិន |
| ៤-ឈ្មោះ ចែម គីមលុច | ៤-ឈ្មោះ ម៉ម សីមុន្នី |

ការបោះឆ្នោតបានបញ្ចប់ជាស្ថាពរនៅវេលាម៉ោងដប់ប្រាំមួយគត់ នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងឯកភាពគ្នា។

បានឃើញ និងឯកភាព
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយកសហគ្រាស

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភី ភី អេស អ៊ី ស៊ី ឯ.ក
P P S E C COMPANY LIMITED
KINGDOM OF CAMBODIA

HWANG SOON JUNG

ហត្ថលេខាអ្នកកត់ត្រា

ហៀល សៃន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អគ្គនាយកដ្ឋានការងារ

នាយកដ្ឋានអធិការកិច្ចការងារ

# បញ្ជីវត្តមាន

តំណាងកម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីពប្រចាំសហគ្រាស គ្រឹះស្ថាន៖ ភី ភី អេស អ៊ី ស៊ី ឯ.ក

ជួបជាមួយក្រុមអធិការកិច្ចការងារទី.......... នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៩ : ១០ នាទី

| ល.រ | គោត្តនាម និងនាម | ភេទ | មុខងារ | ប្រតិភូបុគ្គលិក/សហជីព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| 1 | [illegible] | ប | Sri | ប្រតិភូបុគ្គលិក | 010601630 | |
| 2 | [illegible] | ស | IE | ប្រតិភូបុគ្គលិក | 088 8696691 | |
| 3 | [illegible] | ស | WH | ប្រតិភូបុគ្គលិក | 087743957 | |
| 4 | [illegible] | ស | Packing | ប្រតិភូបុគ្គលិក | 085 244717 | |
| 5 | [illegible] | ប | Admin | ប្រតិភូបុគ្គលិក | 098772269 | |
| 6 | [illegible] | ប | HR Manager | Office | 012988549 | |
| 7. | [illegible] | ស | Admin/HR | Office. | 0969178007 | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក P P S E C COMPANY LIMITED KINGDOM OF CAMBODIA



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ :(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

- បានបញ្ចប់ត្រឹមលេខរៀង.............
- ជួបប្រតិភូបុគ្គលិក និងសហជីព ដោយមានរដ្ឋបាល ☐ គ្មានរដ្ឋបាល ☐
- ចុះសាកសួរព័ត៌មានកម្មករនិយោជិតក្នុងផលិតកម្ម ដោយមានរដ្ឋបាល ☐ គ្មានរដ្ឋបាល ☐